# ជនឥតទទួលខុសត្រូវ !

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២ សីហា ២០០៥

★ ក្នុងឆ្នាំ១៩៦៩ ពេលដែល«សង្គមរាស្ត្រនិយម»បានក្លាយទៅជារបបក្សួយធននៃ«សន្និប្រកាស» (ឈ្មោះភាពយន្តរបស់សីហនុ ដែលមានន័យថា«ព្រះសុរិយាអស្តង្គត»)... សម្តេចសីហនុបានតែងតាំងឧត្តមសេនិយលន់-នល់ជានាយករដ្ឋាភិបាល«ស្រោចស្រង់ជាតិ» ក្នុងប្រការដេញពួកយួនឈ្លានពានចេញពីទឹកដីខ្មែរ ។ រួចហើយស្រាប់តែព្រះមហាវិរៈក្សត្ររត់ទៅចូលយៀកកុង ។

★ ក្នុងឆ្នាំ១៩៧០, សម្តេចសីហនុបានទៅបង្កើតរដ្ឋាភិបាលក្រហមនៅទីក្រុងប៉េកាំង ហើយក៏ពន្យុះពួកខ្មែរក្រហម ឲ្យទៅវាយប្រហាររដ្ឋាភិបាលលន់-នល់ ពោលឲ្យទៅធ្វើការប្រល័យពូជសាសន៍ ទៅលើជនជាតិខ្មែរ ដែលរស់នៅតាមទីក្រុង ។ រួចហើយព្រះអង្គក៏ចោទពួកខ្មែរក្រហមថា ជាពួកឃាតករប្រល័យពូជសាសន៍ ។ សូម្បីតែសព្វថ្ងៃនេះទៀត ព្រះអង្គនៅតែទទួលខ្លួនថា គឺមិនមែនទ្រង់ទេដែលបានទៅចុះចូលខ្មែរក្រហម ប៉ុន្តែគឺពួកខ្មែរក្រហមទៅវិញ ដែលបានរត់មកចុះចូលទ្រង់ ដើម្បីធ្វើការប្រល័យពូជសាសន៍ទៅលើ«ពួករដ្ឋាភិបាលក្បត់លន់នល់-សិរិមតៈ» ។

កាលសម័យនោះ... ជនណាដែលសម្លាប់ពួករដ្ឋាភិបាលលន់-នល់ ត្រូវព្រះអង្គចាត់ទុកថា ជាពួកអ្នកស្នេហាជាតិ... តែក្នុងពេលឥឡូវនេះវិញ ពួកជន«ស្នេហាជាតិ»ដដែល ត្រូវចាត់ទុកថាជាពួកឃាតករទៅវិញ ។ ឃើញថា នៅគ្រប់កាលៈទេសៈទាំងអស់ ស្តេចសីហនុជាជនដែលមិនទទួលខុសត្រូវ... ចេះតែពីលាងដៃស្អាត យកល្អសំរាប់តែខ្លួនឯង ។

★ នៅខែមករា១៩៧៩... ពេលដែលយួនចូលស្រុក... ក្រោមសេចក្តីអង្វររបស់ប៉ុល-ពតនិងចិនប្រជាមានិត ស្តេចសីហនុបានយល់ព្រមឡើងធ្វើសេចក្តីថ្លែងការណ៍ការពារពួករបបឃាតករខ្មែរក្រហម នៅអង្គការសហប្រជាជាតិទីក្រុងញូវយ៉ក ។ ដោយនៅពេលនោះ សីហនុមានចិត្តច្រណែននឹងកិត្តិយសរបស់អៀង-សារី ដែលមាននាទីជានាយកប្រតិភូនៃរដ្ឋាភិបាលខ្មែរក្រហម (ប្រល័យពូជសាសន៍) ព្រះអង្គកើតក្តីក្តៅក្រហាយជាមួយនឹងចិនប្រជាមានិត ហើយក៏បានសំរេចសុំជំរកនយោបាយនៅសហរដ្ឋអាមេរិក ព្រមទាំងសុំទៅសំរាកនៅមន្ទីរពេទ្យឆ្កួតមួយនៅទីក្រុងញូវយ៉ក ។

កន្លែងមន្ទីរពេទ្យឆ្កួតនោះហើយ គួរតែជាទីកន្លែងស្នាក់នៅជាអចិន្ត្រៃយ៍របស់ស្តេចសីហនុ ។ ពីព្រោះថា មនុស្សឆ្កួតហើយនិងជន«ឥតទទួលខុសត្រូវ» គឺជាមនុស្សតែមួយ ទោះសម្លាប់នរណាអស់ប៉ុន្មាននាក់ ក៏គ្មានទោសពៃរ៍អ្វីដែរ ។ ស្រីស្អាតដូចនាងបដាចារ ក៏គ្មាននរណាចង់បានរូបនាងធ្វើជាប្រពន្ធទៀតដែរ ពីព្រោះនាងបានក្លាយទៅជាស្រីឆ្កួតរត់អាក្រាតគ្រប់ទីកន្លែង...។ ចំណែកស្តេចសីហនុទោះជាមានបញ្ហាដល់កំពូលណាក៏ដោយ គឺជា«ស្តេចបដាចារអនាថា» ដែលរត់អាក្រាតគ្រប់ទីកន្លែង (ពោលទ្រង់បានចោទប៉ុល-ពតនិងអៀង-សារី ថាជាពួក«អង្គការលើ-ឃាតករ» ដែលបានពិឃាតព្រះញាតិវង្សស្ទើរម៉ឺនដ្ឋ តែទ្រង់បែរជាមកច្រណែនចង់បានកិត្តិយសរបស់ឃាតករអៀង-សារី នៅអង្គការសហប្រជាជាតិទៅវិញ ?)... ។ ជនឥតទទួលខុសត្រូវ ដែលវង្វេងស្មារតីត្រឡប់ធាតុ បកអាក្រាតតែខ្លួនឯងហាដូច្នេះទៅហើយ មិនត្រូវឲ្យមានឋានៈជាមេភូមិ, មេស្រុក, មេផ្ទះអ្វីទៀតទេ តែត្រូវអនុញ្ញាតសំណាក់នៅជាស្ថាពរក្នុងមន្ទីរពេទ្យឆ្កួត ឬនៅក្នុងវត្តអារាមភាវនាធម៌ដូចនាងបដាចារ ។ ក្នុងប្រការនេះ អ្នកផងមិនយល់ផងសោះ ហេតុអ្វីបានជាមហាអំណាចអាមេរិកាំងហើយនិងចិនបែរជារួបរួមគ្នា រំដោះស្តេចសីហនុយកទៅធ្វើមេដឹកនាំម្តងទៀត ? ។ សូមអានអត្ថបទមួយនៅក្នុង «Prisonnier des Khmers Rouges» របស់នរោត្តម-សីហនុ ៖

នៅ Hotel Waldorf. Astoria ស្តេចសីហនុប្រណែននឹងអៀង-សារី

«នៅក្នុងខែមករា១៩៧៩នោះ គឺខែដែលខ្ញុំគួរតែអបអរសប្បាយនឹងបានទទួលសេរីភាព ខ្ញុំបែរត្រឡប់ជាមកនៅញូវយ៉កទៅវិញ, «ប្រទេសមួយដែលជាចង្កៀងហ្វានៃសេរីភាព», ដោយត្រូវរុំព័ទ្ធនិងឃ្លាំមើលយ៉ាងប្រកិតទាំងថ្ងៃទាំងយប់ ដោយក្រុមពួកមនុស្សរបស់ប៉ុល-ពតនិងអៀង-សារី ។ ពួកនេះមកស្រស់ស្រូបអាហារនៅបន្ទប់បាយរបស់យើង ។ ពួកគេដេកចំខែងនៅក្នុងបន្ទប់ដ៏ថ្លៃបំផុត ដែលរុំព័ទ្ធបន្ទប់របស់យើង ។ ពួកគេធ្វើតាមបណ្តាំនៃមហាថៅកែចិនរបស់យើងមិនឲ្យមានខ្វោះ... ដោយពួកគេពុំមានខ្វះអ្វីឡើយ ៖ នៅលើតុបាយរបស់គេ មានម្ហូបម្ហាដ៏កម្រនិងដ៏ថ្លៃៗជាទីបំផុត ។

«ប្រពន្ធខ្ញុំហើយនិងខ្ញុំ យើងគ្រាន់ហូបសាន់វិច ហើយនិងហ្វ្រម៉ាសតែប៉ុណ្ណោះ ( <u>កកន់</u> ៖ សីហនុទើបនឹងចេញពីគុកប៉ុល-ពត នៅច្រាបជាន់នៅឡើយ... ម្លោះហើយនៅសណ្ឋាគារដ៏ថ្លៃជាងគេបំផុតនៅញូវយ៉ក... សមមិត្តសីហនុហូបតែនំប៉័ងហើយនិងហ្វ្រម៉ាស ) ...ដែលយើងយកទៅហូបក្នុងបន្ទប់របស់យើង ដ៏មានលក្ខណៈជា «មហារាជ» ជាងវាំងខេមរិន្ទទៅទៀត ក្នុងប្រការចៀសវាងកុំឲ្យឃើញពួកឆ្មាំគុករបស់យើង ដែលកំពុងតែច្រាស់ច្រំបោសកណ្តាលដើមទ្រូង ។ ( <u>កកន</u> ៖ សីហនុខ្លាចអង្គការទេតើ បានជាជេរប្រទេចម្លឹងៗ...រួចហើយរត់ទៅបំរើគេធ្លាក់កន្ទុយ ) ។

«មានរឿងពីរយ៉ាងដែលបានធ្វើឲ្យខ្ញុំមានកំហឹងដល់ក...គឺលោកជួន-ប្រសិទ្ធ ដែលនិយាយមកកាន់ខ្ញុំដូច្នេះថា... កិច្ចការហើយនិងបេសកកម្មរបស់សម្តេចនៅក្រុមប្រឹក្សាសន្តិសុខ និងបន្ទាប់នៅមហាសន្និបាតនៃអង្គការសហប្រជាជាតិ នឹងច្បាស់ជាបានទទួលជោគជ័យដ៏ត្រចះត្រចង់ដោយចៀសមិនរួច ពីព្រោះតាំងពីឆ្នាំ១៩៧៥មកទល់ពេលនេះ សមមិត្តអៀង-សារីបានបំពេញដោយជោគជ័យនូវកិច្ចការធំៗ... ពោលគឺបាមណែនាំរដ្ឋដ៏ភាគច្រើនជាអតិបរិមានៅអង្គការសហប្រជាជាតិ ។ ពួកគេស្រឡាញ់រាប់អាន គាំទ្រ និងកោតសរសើរកម្ពុជាប្រជាធិបតេយ្យរបស់យើង ។

«ខ្ញុំដឹងច្បាស់ណាស់អំពីសេចក្តីស្នេហាដ៏ធំធេង ដែលជួន-ប្រសិទ្ធមានចំពោះប៉ុលពត-អៀងសារី, ហើយខ្ញុំក៏យល់ច្បាស់អំពីការប្រមាថមាក់ងាយ និងសេចក្តីស្អប់ខ្ពើមដែលជននេះមានសំរាប់រូបខ្ញុំ និងសំរាប់រាជានិយមខ្មែរ ។ ម្តេចបានជាជននេះមិនយល់ថា សំដីរបស់ខ្លួនជាសំដីឡប់សតិ ? បន្ទាប់ពីពួកអង្គការពត៌មាននៃប្រទេសខាងលិចបាន«ទូង»ជាច្រើនដំបង ទៅលើក្បាលពួកមេដឹកនាំជាទីស្រឡាញ់របស់ខ្លួន ហើយនិងទៅលើក្បាលរបស់ខ្លួនឯង, ហេតុអ្វីបានជាជនម្នាក់នេះ ដែលជាមនុស្សមានបញ្ញា ជាវិស្វករចេញពីសកលវិទ្យាល័យបារាំង នៅមានសង្ឃឹមអ្វីទៀតទៅលើមតិអន្តរជាតិ ចំពោះរបបខ្មែរក្រហមហើយនិងប៉ុលពត-អៀងសារី ដែលជាពួកព្រាយបិសាច ស្រេកឃ្លានលោហិតនៃប្រជាជនរបស់ខ្លួនឯង ? ជួន-ប្រសិទ្ធជាមនុស្សមានប្រាជ្ញាណាស់... មិនមែនមិនដឹងថា សាធារណរដ្ឋប្រជាមានិតចិន ហើយនិងប៉ុលពត-អៀងសារីខ្លួនឯង ដែលបានអង្វរកររូបខ្ញុំឲ្យតំណាងកម្ពុជាប្រជាធិបតេយ្យ គឺដោយហេតុថា រដ្ឋភាគច្រើននៅអង្គការសហប្រជាជាតិ គេចង់ទាក់ទងជាមួយនឹងខ្ញុំ... មិនមែនពួកគេសប្បាយចិត្តនិងអៀង-សារី ឬក៏សូម្បីតែជាមួយខៀវ-សំផននោះផងដែរ ។ ជាការច្បាស់ណាស់ ជួន-ប្រសិទ្ធចង់បំបាក់មុខមាត់របស់ខ្ញុំ ដោយចង់បង្ហាញថា អង្គការមិនមែនត្រូវការរូបខ្ញុំទេ ។ ប៉ុន្តែជនម្នាក់នេះ យល់ខុសហើយ ៖ ខ្ញុំដឹងច្បាស់ណាស់អំពី«ប្រជាប្រិយភាព» និង«កិត្យានុភាព» (Prestige) របស់អៀង-សារីនិងគណបក្សកុម្មុយនិស្តខ្មែរ និងកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវពិភពលោកទាំងមូលក្អួតចង្អោរ, ក្រៅពីប្រទេសមួយក្រុមដែលបានទទួលផលប្រយោជន៍ ក្នុងប្រការប្រើប្រាស់ពួកខ្មែរក្រហមជាគ្រាប់កាណុង ដើម្បីបាញ់សម្លាប់ពួកយៀកណាម ។

«ប្រសិនបើជា«អង្គការ»មិនមានសេចក្តីត្រូវការរូបខ្ញុំយ៉ាងតក្កហលនោះទេ... នៅពេលមួយដែលនាវាកំពុងតែលិច, អង្គការនេះមិនមែនប្រទាញយកខ្ញុំ ចេញពីគុកនៅភ្នំពេញនោះទេ, ហើយនៅថ្ងៃក្រោយមក ក្នុងឆ្នាំ១៩៨២ ក៏មិនបានតែងតាំងរូបខ្ញុំក្លាយទៅជាប្រធានាធិបតីនៃកម្ពុជាប្រជាធិបតេយ្យនោះដែរ... ។

( កកន ៖ ទៅថ្ងៃមុខទៅ នៅពេលដែលអៀង-សារីមកសុំចុះចូលនឹងរបបអាយ៉ងយួនហ៊ុន-សែន, ក៏ស្រាប់តែស្តេចសីហនុចុះហត្ថលេខាលើកលែងទោសឲ្យអៀង-សារី ! ដូច្នេះតើអង្គការសហាប្រជាជាតិធ្វើការកាត់ទោសអៀង-សារីម្តេចនឹងកើតទៅ បើអៀង-សារីជាមេក្លោងអាយ៉ងរបស់យួនផងនិងរបស់ចិនផង ពោលគឺជាចៅហ្វាយនាយរបស់ស្តេចសីហនុ ហើយនិងរបស់ហ៊ុន-សែន ។ នៅក្នុងបច្ចុប្បន្ននេះ ជំនៀខាងលិចនៃប្រទេសកម្ពុជា- ឧត្តរមានជ័យ, ព្រះវិហារ, អន្លង់វែង, ប៉ៃលិន, កោះកុង, កំពង់សោម... ជាទឹកដីកាន់កាប់ដោយអៀង-សារី ចំណែកជំនៀខាងកើត ជាទឹកដីកាន់កាប់ដោយហ៊ុន-សែន ដែលតាមពិតគឺគ្រាន់តែជាកូនចៅ ឬជា«សាវ័ក»របស់អៀង-សារីនិងខៀវ-សំផនទៅវិញសោះ ! ។ គឺបានសេចក្តីថា អំណាចពិតប្រាកដនៅប្រទេសកម្ពុជាសព្វថ្ងៃ ស្ថិតនៅក្នុងកណ្តាប់ដៃអៀង-សារីនិងខៀវ-សំផន ដែលជាអាជ្ញាកណ្តាល... នូវគ្រប់រឿងរ៉ាវអ្វីៗទាំងអស់ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រទី២ ) ។

«រឿងទី២ដែលធ្វើឲ្យខ្ញុំ (ព្រះករុណាខ្ញុំ) ក្រេវក្រោធហួសប្រមាណ គឺខ្ញុំបានទទួលលិខិតមួយពីទីក្រុងប៉េកាំង ដែលប្រាប់ខ្ញុំថា បន្ទាប់ពីមានការបោះឆ្នោតនៃក្រុមប្រឹក្សាសន្តិសុខរួចហើយ ខ្លួនខ្ញុំត្រូវទទួលភារកិច្ចដឹកនាំជា«បណ្តោះអាសន្ន» នូវគណៈប្រតិភូនៃកម្ពុជាប្រជាធិបតេយ្យ សំរាប់មហាសន្និបាតនៃអ.ស.ប. ដោយត្រូវរង់ចាំការអញ្ជើញមកដល់របស់លោកអៀង-សារី, ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុញកិច្ចការបរទេស ដែលមានឋានៈជា «មេដឹកនាំពិតប្រាកដ» នៃគណៈប្រតិភូនេះ ។ ដោយយល់អំពីមហាអប្រជាប្រិយភាពរបស់លោកអៀង-សារីនិងរបស់លោក, ខ្ញុំមិនអាចយល់ស្មានបានបន្តិចសោះថា នៅពេលប្រឈមមុខនឹងបរាជ័យពេញទំហឹងចំពោះពួកវៀតណាម គេបែរជាលើកចំណាត់ការនៃការដឹកនាំប្រតិភូនៃប្រទេសជាតិយើង ទៅឲ្យបុគ្គលម្នាក់ដែលគេស្អប់និងមាក់ងាយពាសពេញពិភពលោក ។ ចំណែកខ្លួនខ្ញុំវិញដែលជាអតិតព្រះមហាក្សត្រ ធ្វើប្រមុខរដ្ឋដល់ទៅ៣ដង ស្រាប់តែគេបែរជា «អាណិតអាសូរ» តែងតាំងរូបខ្ញុំឲ្យធ្វើត្រឹមតែជាភូឈ្នួយរបស់លោកអៀង-សារី សំរាប់មហាសន្និបាតទី១៤នៃអ.ស.ប.ទៅវិញ ! ។ គឺដូចជាការទះកំភ្លៀងមួយដៃយ៉ាងដំណំ ! ។ កិត្តិយសរបស់ខ្ញុំមិនអនុញ្ញាតឲ្យខ្ញុំទ្រាំទ្រការប្រមាថមាក់ងាយបែបនេះទេ ។

«ខ្ញុំបានសំរេចចិត្តរួចហើយ ។ បន្ទាប់ពីថ្ងៃចុងក្រោយនៃមហាសន្និបាត គឺថ្ងៃ១៣មករា១៩៧៩ ហើយបន្ទាប់ពីការបោះឆ្នោតសំរេចជាស្ថាពរនៃក្រុមប្រឹក្សាសន្តិសុខ អំពីទំនាស់រវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ដែលសមាជិកទាំងអស់ (លើកលែងតែឆេកូស្លូវ៉ាគីនិងសូវៀត ដែលបោះឆ្នោតប្រឆាំង) បានដាក់ទោសការរាតត្បាតនៃប្រទេសកម្ពុជា ពីសំណាក់វៀតណាម, ខ្ញុំក៏បានសំរេចចិត្តរំដោះខ្លួនពីការគ្រប់គ្រង ដែលមិនអាចទ្រាំទ្របានរបស់«អង្គការ» » ។

( កកន ៖ គឺបន្ទាប់ពីថ្ងៃនោះហើយ ដែលស្តេចសីហនុបានសំរេចចូលសំរាកនៅមន្ទីរពេទ្យឆ្កួតនៅទីក្រុងញូវយ៉ក ។ ប៉ុន្តែ នៅពេលចេញពីពេទ្យឆ្កួតមកវិញ ស្តេចសីហនុនៅតែឆ្កួតដដែល... គឺបានរត់ទៅធ្វើប្រមុខរដ្ឋនៃការតស៊ូ ឲ្យពួកខ្មែរក្រហមប្រល័យពូជសាសន៍រាប់ឆ្នាំ ទម្រាំបានក្លាយខ្លួនទៅជាព្រះមហាវិរៈក្សត្រ កូនជឹងរបស់ហ៊ុន-សែន... ដែលសំរេចសំរួចទៅ ជាមនុស្សរបស់អៀង-សារីទៅវិញសោះ ។ សាធុ ! សាធុ ! សំពះក្តិតជ្រូក បានបុណ្យបានទាន ! ) ។៚

⌘